# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**អគ្គនាយកដ្ឋានកសិកម្ម**

លេខ.....៣៤១.......អ.ន.ក

ថ្ងៃព្រហស្បតិ៍ ៨ កើត ខែ ផល្គុន ឆ្នាំ រកា សប្តស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០១៨

## សូមគោរពជូន
## ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**កម្មវត្ថុ** : របាយការណ៍ប្រចាំខែកុម្ភៈ ស្តីពីល្បឿនការងារបង្កបង្កើនផលកសិកម្មរដូវប្រាំងឆ្នាំ២០១៧-២០១៨ និងការងារប្រមូលផលស្រូវរដូវប្រាំងឆ្នាំ២០១៧-២០១៨ “ គិតត្រឹមថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៨ ”។

**ជូនភ្ជាប់** : របាយការណ៍លំអិតប្រចាំខែកុម្ភៈ ស្តីពីល្បឿនការងារបង្កបង្កើនផលកសិកម្មរដូវប្រាំងឆ្នាំ២០១៧-២០១៨ និងការងារប្រមូលផលស្រូវរដូវប្រាំងឆ្នាំ២០១៧-២០១៨ “ គិតត្រឹមថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៨ ” ចំនួន០១ច្បាប់។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងជូនភ្ជាប់ខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបថា ល្បឿនការងារបង្កបង្កើនផលកសិកម្មរដូវប្រាំងឆ្នាំ២០១៧-២០១៨ និងការងារប្រមូលផលស្រូវរដូវប្រាំងឆ្នាំ២០១៧ -២០១៨ “ គិតត្រឹមថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៨ ” សម្រេចបាន:

**១. ការងារបង្កបង្កើនផលកសិកម្មរដូវប្រាំងឆ្នាំ២០១៧-២០១៨ :**

**ក. ដំណាំស្រូវ** : ស្ទូង និងព្រោះអនុវត្តបានចំនួន ៥៤២.៥៣៤ ហ.ត ស្មើនឹង ១២២,២៧% នៃផែនការចំនួន ៤៤៣.៧០០ ហ.ត លឿនជាងឆ្នាំមុន ២៧.០៣៧ ហ.ត

**ខ. ដំណាំរួមផ្សំ** : អនុវត្តបាន ១០៣.៨៥៨ ហ.ត លឿនជាងឆ្នាំមុន ១២.៧០៦ ហ.ត

**គ. ដំណាំឧស្សាហកម្ម** : អនុវត្តបាន ១៥.៨៤៩ ហ.ត យឺតជាងឆ្នាំមុន ៣.០១៩ ហ.ត

**២. ការងារប្រមូលផលស្រូវរដូវប្រាំងឆ្នាំ២០១៧-២០១៨ :**

មកដល់ពេលនេះ កសិករនៅតាមបណ្តាខេត្តបន្ទាយមានជ័យ បាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កំពង់ធំ កណ្តាល ក្រចេះ ព្រៃវែង ពោធិ៍សាត់ សៀមរាប ស្វាយរៀង តាកែវ និងខេត្តត្បូងឃ្មុំ បាននិងកំពុងប្រមូលផលស្រូវរដូវប្រាំងលើផ្ទៃដី ១៨៩.៨៣៣ ហ.ត ស្មើនឹង ៣៤,៩៩ %នៃផ្ទៃដីអនុវត្ត ទទួលបានទិន្នផលមធ្យម ៤,២៩០ តោន/ហ.ត និងបរិមាណផលសរុប ៨១៤.៤៥០ តោន។

អាស្រ័យហេតុដូចបានគោរពជូនខាងលើសូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបជាសេចក្តីរាយការណ៍ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

**ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក**
**នៃអគ្គនាយកដ្ឋានកសិកម្ម**

**បណ្ឌិត ហ៊ាន វណ្ណហាន**

**ចំលងជូន ៖**
- ឯកឧត្តមរដ្ឋលេខាធិការទទួលបន្ទុកអគ្គនាយកដ្ឋានកសិកម្ម
- ឯកឧត្តម លោកជំទាវ អនុរដ្ឋលេខាធិការទទួលបន្ទុកអគ្គនាយកដ្ឋានកសិកម្ម
- ឯកឧត្តមអគ្គលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ "ដើម្បីគោរពជូនជ្រាប"
- នាយកដ្ឋានកិច្ចការរដ្ឋបាល
- នាយកដ្ឋានផែនការ និងស្ថិតិ
- នាយកដ្ឋានពាក់ព័ន្ធរបស់អគ្គនាយកដ្ឋានកសិកម្ម
- ឯកសារ កាលប្បវត្តិ


អាសយដ្ឋានលេខ: ៥៤បេ/៤៩អេហ្វ ផ្លូវលេខ ៣៩៥-៦៥៦ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ទូរស័ព្ទលេខ:(០២៣) ៨៨៣ ៤២៧ ទូរសារលេខ:(០២៣) ៨៨៣ ៤២៧
Address # 54B/49F, Street 395-656, Sangkat Toeuk Laak 3, Khan Tuol Kok, Phnom Penh. Cambodia, Phone : (023) 883 427, Fax : (023) 883 427